**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
**MINISTRY OF INFORMATION**

លេខ ១១៣៤ ព.ម

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧

# ជម្រាបមក

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ស្ថានីយវិទ្យុ-ទូរទស្សន៍
គ្រប់ប្រព័ន្ធ ចាងហ្វាងកាសែត ទស្សនាវដ្ដី ព្រឹត្តិប័ត្រ ទាំងអស់

__កម្មវត្ថុ:__ ស្ដីពីការផ្សាយស្ប៉តពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹងផ្ដល់រង្វាន់នៅតាមប្រព័ន្ធផ្សព្វផ្សាយទាំងអស់។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីម្ចាស់ស្ថានីយវិទ្យុ-ទូរទស្សន៍ ចាងហ្វាងកាសែត ទស្សនាវដ្ដី ព្រឹត្តិប័ត្រទាំងអស់ជ្រាបថា បច្ចុប្បន្នមានការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងយ៉ាងគគ្រឹកគគ្រេងនៅតាមស្ថានីយវិទ្យុ-ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយនានា ដោយមានការផ្ដល់រង្វាន់ផ្សងសំណាងយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីអូសទាញប្រជាពលរដ្ឋ និងជាពិសេសស្រទាប់យុវជន ដែលជាទំពាំងស្នងឬស្សីឲ្យឈ្លក់វង្វេងដោយការសេពគ្រឿងស្រវឹងដើម្បីផ្សងយករង្វាន់ដែលធ្វើឲ្យប៉ះពាល់ដល់អនាគតរបស់យុវជនខ្មែរ ខាតបង់ថវិការបស់ប្រជាពលរដ្ឋ បង្កគ្រោះថ្នាក់ចរាចរណ៍ និងកើតមានអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាក្នុងសង្គម ការចាប់រំលោភសេពសន្ថវៈជាដើម។

ដើម្បីជៀសវាងនូវភាពអសកម្មខាងលើ និងរួមចំណែកកសាងធនធានមនុស្ស ការអភិវឌ្ឍប្រទេសជាតិ ការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ អំពើហិង្សាក្នុងសង្គម ការរំលោភសេពសន្ថវៈ ។ល។ ក្រសួងព័ត៌មានសូមធ្វើការណែនាំរំលឹកជាថ្មីម្ដងទៀតដល់ម្ចាស់ស្ថានីយវិទ្យុ-ទូរទស្សន៍ និងម្ចាស់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ឲ្យអនុវត្តដូចខាងក្រោម៖

-អនុញ្ញាតឲ្យផ្សព្វផ្សាយស្ប៉តពាណិជ្ជកម្មគ្រឿងស្រវឹងដោយមានការផ្ដល់រង្វាន់តែក្នុងរយៈពេលមុន និងក្រោយ១៥ថ្ងៃ នៃថ្ងៃបុណ្យចូលឆ្នាំខ្មែរ ចូលឆ្នាំចិន និងពិធីបុណ្យអុំទូកប៉ុណ្ណោះ។ ក្រៅពីនេះ ក្រសួងព័ត៌មានមិនអនុញ្ញាតឲ្យធ្វើការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងផ្ដល់រង្វាន់ឡើយ។ ចំពោះក្រុមហ៊ុនណាដែលមានបំណងចង់ផ្សព្វផ្សាយស្ប៉តពាណិជ្ជកម្មគ្រឿងស្រវឹងផ្ដល់រង្វាន់ ត្រូវសុំការអនុញ្ញាតពីក្រសួងព័ត៌មានជាមុនសិន។

-បញ្ឈប់ការផ្សព្វផ្សាយស្ប៉តពាណិជ្ជកម្មគ្រឿងស្រវឹងដោយប្រើសកម្មភាព ឬរូបភាពដែលមានលក្ខណៈអូសទាញប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យឲ្យឈ្លក់វង្វេងសេពគ្រឿងស្រវឹង។

ដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ប្រព័ន្ធ-ផ្សព្វផ្សាយទាំងអស់សហការអនុវត្តសេចក្ដីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ក្នុងករណីមិនអនុវត្តតាមសេចក្ដីជូនដំណឹងនេះ ក្រសួងព័ត៌មាននឹងដកហូតអាជ្ញាប័ណ្ណបញ្ឈប់ការធ្វើអាជីវកម្មស្ថានីយវិទ្យុ-ទូរទស្សន៍ ឬអង្គភាពផ្សព្វផ្សាយនោះជាស្ថាពរ។

សូមឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីទទួលនូវការរាប់អានដ៏កក់ក្ដៅពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

__ចម្លងជូន__
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា-រដ្ឋសភា
- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្ដេចតេជោហ៊ុនសែននាយករដ្ឋមន្ត្រី
- -ក្រសួងសុខាភិបាល
- -សមាគមវិទ្យុកម្ពុជា-សមាគមទូរទស្សន៍កម្ពុជា-សមាគមអ្នកសារព័ត៌មាន
- -ឯកសារ

អាសយដ្ឋាន: អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ